ព្រះរាជាណាចក្រ កម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី
សំណុំរឿង រដ្ឋប្បវេណី
លេខ:៨៥
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៩
<u>សាលដីកា</u>
លេខ:០៧
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម **ឌឹត មុន្នី** ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក **ប៉ែន ស៊ុន** ជាចៅក្រម
៣-លោក **វៀល មួន** ជាចៅក្រម
៤-លោក **ជីវ កេង** ជាចៅក្រម

៦-លោក **សោម សិរីវុឌ្ឍន៍** ជាចៅក្រមរបាយការណ៍

<u>ក្រឡាបញ្ជី</u>
-លោក **ឈិត បូរ៉ាវុធ**

<u>តំណាងមហាអយ្យការ</u>
-លោក **ជូន ស៊ុនឡេង** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ០២ ចុះថ្ងៃទី០៤-០១-៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៧៨ ចុះថ្ងៃទី១៧-០៨-៩៨ របស់សាលាឧទ្ធរណ៍។

-វាង៖ ១-ដើមចោទឈ្មោះតា. រដ្ឋាភិរម្យ អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរប្រធានក្រុមហ៊ុនមេត្រូផ្លេកស៍ មានទីលំនៅ ផ្ទះលេខ៧០CDE₀ ផ្លូវ១១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។ ផ្ទេរឲ្យឈ្មោះ តា. រដ្ឋាមតៈ (ជាចុងបណ្តឹងសាទុក្ខ)

២-ឈ្មោះ ឃួន. ផល្លាវិទ្ធ អាយុ ៤២ ឆ្នាំ ជាតិខ្មែរ មុខរបរ ប្រធានក្រុមហ៊ុន មេត្រូផ្លេកស៍ មានទីលំនៅផ្ទះលេខ៣៨E0 ផ្លូវ៩៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ (ជាចុងបណ្តឹងសាទុក្ខ)

មានលោកស្រី មួង ធនលាភី ជាមេធាវី

- ចុងចម្លើយឈ្មោះ សុខ. ខឿន ហៅចេង អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះមានទីលំនៅផ្ទះលេខ ៨៩៨ E0 ផ្លូវកម្ពុជាក្រោម សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ (ជាចុងបណ្តឹងសាទុក្ខ)

និងតតីយជន ជាម្ចាស់បណ្តឹងសាទុក្ខ

១-ឈ្មោះ សេង រតនៈ អាយុ៤៣ ឆ្នាំ ជាតិខ្មែរ មុខរបរ អភិបាលខណ្ឌឫស្សីកែវ មានទីលំនៅ ផ្ទះលេខ ១៣ ផ្លូវលេខ២៥០ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

មានលោក កែត. ឃី ជាមេធាវី

២-ឈ្មោះ ជុំ សារ៉ាយ អាយុ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរ ចៅសង្កាត់ភ្នំពេញថ្មី មានទីលំនៅផ្ទះលេខ១១ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៣-ឈ្មោះ គង់ សាខន អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរ អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នៃ ក្រសួង អភិវឌ្ឍន៍ជនបទ មានទីលំនៅផ្ទះលេខ១៤CE0 ផ្លូវ៣៩២ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៤-ឈ្មោះទូច សាឡាស់ អាយុ៤៧ ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ មានទីលំនៅផ្ទះលេខ៤៥ $E_1$ ផ្លូវ១១៨ ក្រុម៣២ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**<u>កម្មវត្ថុបណ្ដឹង:</u>** ប្ដឹងសុំសិទ្ធិគ្រប់គ្រង និងកាន់កាប់ដី

តាមពាក្យបណ្ដឹង ចុះថ្ងៃទី១២-០៥-៩៧ របស់ដើមចោទប្ដឹងសុំសិទ្ធិគ្រប់គ្រងកាន់កាប់ប្រើប្រាស់ដី ទំហំ២០.៤៦៤.១៩៥ម$^{២}$ ស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ពីឈ្មោះ សេង សំណាង ប្រពន្ធឈ្មោះ សុខ. ខឿន ហៅ សុខ ចេង ។ ដោយហេតុថា ឈ្មោះ សេង សំណាង បានលក់ដីជាងពីរហិកតា តាមប្លង់ជូនលោក តា. វឌ្ឍាភិរម្យ និងឈ្មោះ ឃួន. ផល្លាវិទ្ធិ ។ ឈ្មោះ សេង សំណាង ក៏បានផ្ទេរសិទ្ធិឲ្យទៅឈ្មោះ តា. វឌ្ឍាភិរម្យ និងឈ្មោះ ឃួន. ផល្លាវិទ្ធិ នៅចំពោះមុខចៅសង្កាត់ភ្នំពេញថ្មី មុននឹងរដ្ឋអំណាចមូលដ្ឋានចុះវាស់វែងដើម្បីផ្ទេរកម្មសិទ្ធិ ប្រធានការិយាល័យភូមិបាល ខណ្ឌឫស្សីកែវ បានចេញសេចក្ដីជូនដំណឹងមុនថា បើមានអ្នកពាក់ព័ន្ធ សូមមកបំភ្លឺតាមការដាក់ស្ដែង ប៉ុន្តែតាំងពីថ្ងៃទី១៦-១២-៩៦ មកទល់សព្វថ្ងៃនេះ គ្មានអ្នកណាជំទាស់ពីបញ្ហាដីនេះទេ ។ តែបែរជាឈ្មោះ ជុំ សារ៉ាយ ចៅសង្កាត់ភ្នំពេញថ្មីចេញលិខិត ចុះថ្ងៃទី០៩-០៤-៩៧ បដិសេធការចុះហត្ថលេខារបស់ខ្លួន និងបដិសេធ ហត្ថលេខាលោក ឃ្លាំង សោភ័ណ្ឌ ចៅសង្កាត់រងទីមួយទៅវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១២០(គ) ចុះថ្ងៃទី២៤-១២-៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី១២-០៥-១៩៩៧ របស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-ទទួលសំណូមពររបស់តតីយជនទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-ប្រគល់ដី ទំហំ២០៤៦៤.១៩៥ម² (តាមគំនូសផែនទីបង្ហាញទីតាំងដី ចុះថ្ងៃទី២២-១១-៩៦ របស់ចៅសង្កាត់ភ្នំពេញថ្មី) ស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ឲ្យទៅឈ្មោះ ឃួន, ផល្លាវិទ្ធិ និងតា. រដ្ឋាភិរម្យ ដែលមានមេធាវី មួង, ធនលាភី ជាតំណាងគ្រប់គ្រងកាន់កាប់ប្រើប្រាស់ ចាប់តាំងពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។

៤-ឲ្យឈ្មោះសុខ. ខឿន ហៅ ចេង និងប្តីឈ្មោះ សេង សំណាង ប្រគល់ប្រាក់ថ្លៃដី ចំនួន១០០០០ (មួយម៉ឺន)ដុល្លារអាមេរិក ឲ្យទៅលោក សេង រតនៈ ។ ករណីរឹងទទឹងពុំព្រមសង ត្រូវដាក់គុកបង្ខំលើរូបកាយ និងរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង ដើម្បីជានាសំណង តាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-ឲ្យឈ្មោះ ជុំ សារ៉ាយ ប្រគល់ប្រាក់ថ្លៃដី ចំនួន៤៥០០ (បួនពាន់ប្រាំរយ)ដុល្លារអាមេរិក ឲ្យទៅលោក ទូច, សាឡាស់. ប្រគល់ប្រាក់ចំនួន៥០០០(ប្រាំពាន់)ដុល្លារអាមេរិក ឲ្យទៅលោក គង់ សាខន និងប្រគល់ប្រាក់ថ្លៃដីតាមការទាមទាររបស់លោក ញឹក សារ៉េត ឲ្យទៅឈ្មោះ ញឹក សារ៉េត ។ ករណីរឹងទទឹងពុំព្រមសង ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង ដើម្បីជានាសំណងតាមច្បាប់ ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៦-ឲ្យឈ្មោះសុខ ខឿន ហៅ ចេង និងប្តីឈ្មោះ សេង សំណាង បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជី និងពន្ធហ្នឹងចំនួន១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល បូករួម៧០០០រៀល ដែលដើមចោទ បានបង់ទុកជាស្រេច ។ កាលបើហួសបណ្តឹងឧទ្ធរណ៍ហើយ បង្គាប់ឲ្យឈ្មោះ សុខ ខឿន ហៅ ចេង និងប្តីឈ្មោះ សេង. សំណាង សងប្រាក់៧០០០រៀល ឲ្យទៅដើមចោទវិញ និងឲ្យឈ្មោះ សុខ ខឿន ហៅ ចេង និងប្តីឈ្មោះ សេង សំណាង បង់ពន្ធសមាមាត្រមួយភាគរយលើប្រាក់១០.០០០(មួយម៉ឺន) ដុល្លារអាមេរិក ។ ឲ្យឈ្មោះ ជុំ សារ៉ាយ បង់ពន្ធសមាមាត្រចំនួនមួយភាគរយ លើប្រាក់ ៩៥០០ (ប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក ។ ប្រាក់ពន្ធសមាមាត្រនេះត្រូវដាក់ចូលថវិការដ្ឋចំនួន៨០ភាគរយ និងជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន២០ភាគរយ តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៧-សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី និងតតីយជនលោក គង់ សាខន លោក ជុំ សារ៉ាយ លោក ទូច សាឡាស់ កំបាំងមុខ តតីយជនលោក សេង រតនេៈ លោក ញឹក សារ៉េត សម្រេចបើកផ្លូវឧទ្ធរណ៍ ក្នុងរយៈពេលពីរខែ គិតពីថ្ងៃ ផុតបណ្តឹងទាស់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៦ (គ) ចុះថ្ងៃទី១៦-០២-៩៨ របស់ឈ្មោះសុខ ខឿន ហៅ ចេង ប្តឹងឧទ្ធរណ៍ ត្រង់ចំណុចទី៤ នៃសេចក្តីសម្រេចនៃសាលក្រម ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ១០ ចុះថ្ងៃទី២៣-០២-៩៨ របស់ឈ្មោះ ជុំ សារ៉ាយ ប្ដឹងឧទ្ធរណ៍ត្រង់ចំណុចទី៣ និងទី៥ នៃសេចក្ដីសម្រេចនៃសាលក្រម ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ០២ ចុះថ្ងៃទី០៤-០១-៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦-០២-៩៨ និងចុះថ្ងៃទី២៣-០២-៩៨ របស់ដើមបណ្ដឹងឧទ្ធរណ៍ឈ្មោះសុខ ឃឿន ហៅ ចេង និងរបស់ឈ្មោះ ជុំ សារ៉ាយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១២០(គ) ចុះថ្ងៃទី២៤-១២-៩៧ ទុកជាបានការ ប៉ុន្តែចំណុចទី២-៤ និង៥ ត្រូវបដិសេធចោលជាអាសារបង់ និងកែប្រែពន្ធសមាមាត្រជាថ្មី ។

៣-ទុកសិទ្ធិឲ្យឈ្មោះគង់ សាខន ប្ដឹងទាមទារដី ឬ ប្រាក់ពីឈ្មោះ ជុំ សារ៉ាយ ។

៤-សម្រេចកាត់យកប្រាក់ប្រដាប់ក្ដី នៅជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍ បានបង់ទុក រួចហើយ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ៤៥០ រៀល ចំណាយលើការប្រគល់ដីកាកោះ ៥០០០ រៀល និងលើអាជ្ញាធរតុលាការ ៥០០០ រៀល ។

-កាលបើហួសកំណត់ប្ដឹងសាទុក្ខ បង្គាប់ឲ្យឈ្មោះគង់ សាខន ទូច សាឡាស់ និង សេង រតនៈ សងប្រាក់ ១៣០០០រៀល ទៅដើមបណ្ដឹងឧទ្ធរណ៍វិញ និងបង្គាប់ឲ្យ គង់ សាខន ទូច សាឡាស់ និង សេង រតនៈ បង់ពន្ធសមាមាត្រមួយភាគរយ លើតម្លៃដីទំនាស់ ។

៥-សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធរណៈ ចំពោះមុខមេធាវីដើមចោទ ឈ្មោះ មួង ធនលាភី លោក គង់ សុភ័ក្រ. ឈ្មោះ សុខ ខឿន តំណាង លោក សេង រតនៈ ឈ្មោះ ឃ្លាំង សារិ លោក គង់ សាខន និងលោក ទូច សាឡាស់ ។

- បើកផ្លូវប្ដឹងតវ៉ាក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងសាទុក្ខលេខ១៩ ចុះថ្ងៃទី១៤-០១-៩៩ របស់ឈ្មោះសេង រតនៈ ប្ដឹងតវ៉ាត្រង់ចំណុចទី២ នៃសាលដីការបស់សាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ៦៥ ចុះថ្ងៃទី២៥-០២-៩៩ របស់ឈ្មោះគង់ សាខន ប្ដឹងតវ៉ាពីសេចក្ដីសម្រេចទាំងមូល នៃសាលដីកា របស់សាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាការពារ ចុះថ្ងៃទី២០-០៥-៩៩ របស់ឈ្មោះ សេង រតនៈ ។

-បានឃើញសារណាការពារ ចុះថ្ងៃទី១៥-០៦-៩៩ របស់ឈ្មោះ គង់ សាខន ។

-បានឃើញសារណាការពារ ចុះថ្ងៃទី២៣-០៦-៩៩ របស់ឈ្មោះ ទូច សាឡាស់ ។

-បានឃើញសារណាការពារ ចុះថ្ងៃទី០៨-០៧-៩៩ របស់លោកមេធាវី គង់ សុភ័ក្រ តំណាងឲ្យឈ្មោះ ជុំ សារ៉ាយ ។

-បានឃើញសារណាតប ចុះថ្ងៃទី០៨-០៧-៩៩ របស់ឈ្មោះសុខ. ខឿន ហៅ ចេង ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: សាលដីការដ្ឋប្បវេណីលេខ០២ ចុះថ្ងៃទី ០៤-០១-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ ហើយ ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយដោះសាររបស់ឈ្មោះ សេង រតនៈ ឆ្លើយក្នុងពេលសវនាការថា៖ បានជាខ្ញុំបាទប្តឹងមកតុលាការកំពូល ដោយមូលហេតុថា ខ្ញុំបាទមានដីមួយទំហំ២០ម គុណ ៦០ម ស្ថិតនៅខាងលិចដីរុក្ខាប្រមាញ់ជាប់ផ្លូវចូលវត្តសំរោងអណ្តែត ដែលមានព្រំជាប់ដី លោក សុខ ណោ ផ្លូវចូលវត្តសំរោងអណ្តែត ។ ដីនេះខ្ញុំសុំពីសង្កាត់ភ្នំពេញថ្មី តាំងពីខែ វិច្ឆិកា ឆ្នាំ ១៩៩០ នៅឆ្នាំ ១៩៩៣ លោក ឡៅ ឈួន បានសុំទិញខ្ញុំតាមតម្លៃឯកភាពគ្នា ៥០០០(ប្រាំពាន់)ដុល្លារអាមេរិក ហើយកក់មុន៥០០ (ប្រាំរយ) ដុល្លារអាមេរិក ដោយកំណត់រយៈពេលមួយខែ ការទិញលក់នេះ ពុំបានធ្វើលិខិតទិញ-លក់ ទេ គឺគ្រាន់តែមានសាក្សីម្នាក់ គឺលោក នួន ឈន លុះដល់ថ្ងៃ២៨-១២-៩៤ ប្រពន្ធលោក ឡៅ ឈន ឈ្មោះ គុំ សាខឿន មកអង្វរខ្ញុំបាទឲ្យ ទទួលប្រាក់បង្គ្រប់ កុំឲ្យដាច់ប្រាក់កក់ តែចំនួន លុយមានតែ ៣៥០០ (បីពាន់ប្រាំរយ)ដុល្លារអាមេរិក ដោយខ្ញុំរវល់ពេកខ្ញុំឲ្យទុកប្រាក់នៅទីនេះចុះ ឲ្យទៅយកប្រាក់១០០០ (មួយពាន់)ដុល្លារអាមេរិក ទៀតមកបង្គ្រប់ ប៉ុន្តែពេលទៅអ្នកស្រី គុំ សាខឿន ទៅបាត់ មិនឃើញមកវិញសោះ ។

ដល់ថ្ងៃទី៣០-១២-៩៤ ខ្ញុំបាទបានយកប្រាក់៣៥០០ ដុល្លារអាមេរិក ទៅប្រគល់ឲ្យអ្នកស្រី គុំ សាខឿន ដោយធ្វើ លិខិតស្នាម និងកត់ត្រាលេខលុយក្រដាស១០០ គ្រប់ចំនួន៣៥សន្លឹក មានអ្នកដឹងឮគឺ លោក ជុំ សារ៉ាយ ទួន ឈន និង ឃឹម. ចំរើន ។ ចំណុចនេះបញ្ជាក់ច្បាស់លាស់ថា ខ្ញុំបាទមានដីយ៉ាងពិតប្រាកដ បើខ្ញុំគ្មានដី គឺមិនអាចឈានទៅធ្វើការទិញ-លក់ មានការកក់លុយ មានធ្វើការប្រគល់លុយវិញយ៉ាងនេះទេ ។ ចំពោះបញ្ហានេះ និយាយរួមគឺ គាត់ទិញដីឲ្យគេ មិនគ្រប់ក្បាលដី ទើបសុំទិញដីពីខ្ញុំ ការសុំទិញ នេះគឺខែធ្នូ ឆ្នាំ១៩៩៦ លោក សូ ណន បានមកអង្វរខ្ញុំថា អ្នកទិញដីពី ឡៅ ឈួន និង ឆាយ មន នោះគឺជាក្មួយគាត់ ឈ្មោះ សុខ ឃឿន ឲ្យខ្ញុំលក់ដើម្បីបំពេញជ្រុង ខ្ញុំបាទសុខចិត្តលក់ឲ្យក្នុងតម្លៃ៥០០០ ដុល្លារ ដដែល ប៉ុន្តែរហូតមកដល់ពេលនេះ អ្នកស្រី សុខ. ឃឿន ប្រពន្ធរបស់ សេង សំណាង មិនយកប្រាក់មកប្រគល់ឲ្យខ្ញុំទេ ហើយយកដីខ្ញុំទៅលក់ឲ្យ តា រដ្ឋាភិរម្យ និង យួន,ផល្លាវិទ្ធិ ។ ការលក់-ទិញនេះ ខ្ញុំពុំបានដឹងទេ ទើបនៅដើមឆ្នាំ១៩៩៧ ឃើញគេចាក់ដីទើបខ្ញុំឃាត់ប្តឹងមកតុលាការ ។

រឿងនេះគួរតែសាលាឧទ្ធរណ៍ ចុះទៅដល់ទីកន្លែងដី សួរនាំឲ្យច្បាស់ធ្វើការអង្កេត តែសាលាឧទ្ធរណ៍បែរជាសម្រេចតែម្តង ដូច្នេះ ខ្ញុំបាទពុំអស់ចិត្តឡើយ ខ្ញុំបាទសំណូមពរ សុំឲ្យតុលាការកំពូលបដិសេធ រួចបញ្ជូនឲ្យសាលាឧទ្ធរណ៍ធ្វើការអង្កេតឡើងវិញ មុននឹងជំរះក្តី ដោយចុះទៅវាស់វែង សួរសាក្សីឲ្យបានគ្រប់គ្នាចំពោះអ្នកពាក់ព័ន្ធ ។

បានស្តាប់ចម្លើយដោះសាររបស់ឈ្មោះទូច សាឡាស់ ឆ្លើយក្នុងពេលសវនាការថា នៅក្នុងឆ្នាំ ១៩៩២ ខ្ញុំបាទបានទិញដី១កន្លែង មានសំបុត្រស្នាមរបស់រដ្ឋអំណាចខ្ញុំបាទពុំដឹងថា គេយកដីរបស់ខ្ញុំទៅលក់ទេ ខ្ញុំបាទសូមឲ្យក្រុមប្រឹក្សាជំនុំជំរះ រកយុត្តិធម៌ឲ្យខ្ញុំបាទផង ។ដីនេះមានបោះបង្គោលជាចំណាំ អ្នកយកដីលក់គឺខ្ញុំអត់ដឹងទេ ឃើញតែគេចាក់ដី ទើបខ្ញុំទៅសួរ ជុំ សារ៉ាយ គាត់ថាចាំគាត់ ប្រាប់គេឲ្យឈប់ចាក់ ប៉ុន្តែតាមការពិត លោក ជុំ សារ៉ាយ គាត់នៅតែចាក់ ។ ក្នុងរឿងនេះ លោក ឃួន. ផល្លារិទ្ធិ ថាលោក ជុំ សារ៉ាយ ជាអ្នកម៉ៅការចាក់ដីរយៈពេល១ខែ ដីនេះមានទំហំ២៥ម គុណ ៣០ម ។ នៅតុលាការក្រុងភ្នំពេញ កាត់ឲ្យខ្ញុំ ៤០០០ ដុល្លារអាមេរិក គឺឲ្យ ជុំ .សារ៉ាយ សងមកខ្ញុំ៤០០០ ដុល្លារ សងលោក សាខន៥០០០ ដុល្លារ ដល់មកដល់សាលាឧទ្ធរណ៍ គេឲ្យខ្ញុំប្តឹងពី ឆាយ ម៉ន ។ ចំពោះរឿងនេះ ខ្ញុំបាទសុំប្តឹងយកដីវិញក៏បាន យកជាប្រាក់ក៏បាន ចំពោះប្រាក់ គឺសុំដូចនៅតុលាការក្រុងភ្នំពេញ ។

បានស្តាប់ចម្លើយដោះសារបស់ឈ្មោះ គង់ សាខន ឆ្លើយក្នុងពេលសវនាការថា៖ បានជាខ្ញុំបាទមិនសុខចិត្តពីសាលដីកា សាលាឧទ្ធរណ៍ ដោយសារខ្ញុំបាទមានដីមួយកន្លែង តែគេយកដីខ្ញុំទៅលក់ សាលាឧទ្ធរណ៍លើកឡើងថា៖ ការណ៍ដែលខ្ញុំឲ្យលុយលោក ជុំ សារ៉ាយ ទៅទិញដីនោះមិនដឹងជា ជុំ សារ៉ាយ បានទិញឬក៏អត់ក៏មិនដឹង មិនអាចយកជាសំអាងបានឡើយ គឺពុំត្រឹមត្រូវទេ ព្រោះលោក ជុំ សារ៉ាយ បានប្រាប់ខ្ញុំថា បានទិញរួចហើយ មានទាំងលិខិតស្នាម ហើយបានទៅចង្អុលបង្ហាញដីនេះ ដោយយកបង្គោលចំនួន០៤ ទៅបោះ ទៀតផង ។ ការណ៍ដែលឲ្យ ជុំ សារ៉ាយ ទិញឲ្យគឺដីមានទំហំ២៤ម គុណ ២៥ម ដោយមានបង្កាន់ដៃទទួលស្គាល់ពីកសិកម្មស្រុក ដីនេះ ខ្ញុំទៅមើលពីរបីខែម្តង លុះដល់ចុងឆ្នាំ១៩៩៦ ឃើញគេចាក់ដីលើដីរបស់ខ្ញុំ ខ្ញុំក៏ទៅដល់សង្កាត់ សង្កាត់គេប្រាប់ថាខ្ញុំថាផ្អាកហើយ ចំពោះការចាក់របស់ក្រុមហ៊ុននេះ ។ ដីនេះខ្ញុំបាទសន្និដ្ឋានថា លើកទី១ គេមិនទាន់លក់ទេ តែខ្ញុំក៏សង្ស័យថា លួចលក់លើកទី២ សំណូមពរ សុំយកដីវិញ ។

## ក្រឡាបញ្ជីអានសារណារបស់ ឈ្មោះ ជុំ សារ៉ាយ

បានស្តាប់ចម្លើយដោះសារបស់ឈ្មោះសុខ ខឿន ឆ្លើយក្នុងពេលសវនាការថា៖ ក្នុងឆ្នាំ១៩៩២ នាងខ្ញុំបានទិញដីនេះ ដោយមានចុះហត្ថលេខាពី ជុំ សារ៉ាយ ឆាយ ម៉ន លុះដល់ឆ្នាំ១៩៩៦ នាងខ្ញុំក៏លក់ដីនេះឲ្យទៅលោក តា រដ្ឋាភិរម្យ ផល្លារិទ្ធិ ការលក់-ទិញ នេះ គឺសុទ្ធតែធ្វើការប្រកាសត្រឹមត្រូវ គ្មានឃើញអ្នកណាមកតវ៉ា ។ ការទិញនេះ គឺដីមានទំហំ១៨៣៤០ម$^{២}$ មានបង្កាន់ដៃលេខ២៥៥១៧ និងលេខ

២១៥៨៩ ពីឈ្មោះ ឆាយ ម៉ន ដោយមានកិច្ចសន្យាផ្ទេរសិទ្ធិចំពោះមុខសាក្សី ឈ្មោះ ញែម ផល្លា យឹម. ណារិទ្ធិ និងមានមេភូមិ ឈ្មោះ ចាន់ ហន តំណាងកសិកម្មឈ្មោះ នួន ឈន និងលោក ជុំ សារ៉ាយ ជាអ្នកគូសទីតាំងទំហំដីផង ។ លុះដល់ថ្ងៃទី២៦-០៦-៩៦ នាងខ្ញុំក៏បានលក់ដីនេះបន្តឲ្យ ឃួន ផល្លារិទ្ធិ និង រដ្ឋាភិរម្យ តាមកិច្ចសន្យាទិញ-លក់១ម$^{២}$ តម្លៃ៥,២ ដុល្លា ។

ទំហំដីវាស់ជាក់ស្តែងសរុប ដែលនាងខ្ញុំលក់ឲ្យឈ្មោះ ឃួន,ផល្លារិទ្ធិ និងតា រដ្ឋាភិរម្យ គឺទំហំ ២០៤៦៤.១៩៥ម$^{២}$ ។នាងខ្ញុំសូមបញ្ជាក់ថា រាល់ការផ្ទេរសិទ្ធិពី ឆាយ ម៉ន មកនាងខ្ញុំ និងពីនាងខ្ញុំទៅឃួន ផល្លារិទ្ធិ និង តា រដ្ឋាភិរម្យ តែងតែធ្វើចំពោះមុខចៅ សង្កាត់ ជុំ សារ៉ាយ និងចៅសង្កាត់រង ឃ្លាំង. សោភ័ណ ជាអ្នកចាត់ការ ។ នាងខ្ញុំសុំឲ្យតុលាការកំពូល មេត្តាតម្កល់សាលដីការបស់ សាលាឧទ្ធរណ៍ ។

- ក្រឡាបញ្ជីអានសារណា តា. រដ្ឋាភិរម្យ

- មេធាវី ធ្វើសេចក្តីសន្និដ្ឋាន

**មេធាវី កែត ឃី**

កូនក្តីខ្ញុំបាទពិតជាមានដីមួយកន្លែង ហើយបានលក់ក្នុងតម្លៃ៥០០០ដុល្លារ ប៉ុន្តែដោយការលក់នេះ ភាគីអ្នកទិញមិនឲ្យលុយ គ្រប់ ទើបកូនក្តីខ្ញុំយកលុយទៅប្រគល់ឲ្យ សុខ ខឿន វិញ ដោយមានធ្វើលិខិតស្នាម កត់លេខលុយ តាមលេខថែមទៀត ។ ឆ្នាំ១៩៩៦ អ្នកស្រី សុខ ខឿន ហៅ ចេង បានទៅពឹងលោក ស៊ូ ណន អភិបាលរងឫស្សីកែវ ឲ្យមកជួយនិយាយឲ្យកូនក្តីខ្ញុំបាទលក់ដីឲ្យខ្លួន ដើម្បីបំពេញជ្រុង ដោយលោក សេង រតនៈ យល់ដល់លោក ស៊ូ ណន ទើបយល់ព្រមលក់ក្នុងតម្លៃ ៥០០០ ដុល្លារ ដដែល ប៉ុន្តែដោយអ្នកស្រី សុខ ខឿន មិនបានយកប្រាក់មកប្រគល់ឲ្យកូនក្តីខ្ញុំ ហើយថែមទាំងបានយកដីនេះ ទៅលក់ឲ្យ តា រដ្ឋាភិរម្យ បន្តទៀត ។

ការណ៍ដែលសាលាឧទ្ធរណ៍ យល់ឃើញថា លោក សេង រតនៈ មិនដឹងប្រវត្តិដីនេះយ៉ាងណានោះ គឺពុំត្រឹមត្រូវឡើយ ព្រោះដីនេះ ចៅសង្កាត់ភ្នំពេញថ្មី ជុំ សារ៉ាយ បានប្រគល់ឲ្យតាំងពីឆ្នាំ១៩៩០ មកម្ល៉េះ ហើយកាន់កាប់មានរដ្ឋអំណាចភូមិ-ឃុំ និងអ្នកជាប់ព្រំដឹងឮគ្រប់គ្នា ។ ឃើញថាស្របតាមមាត្រា ៦២.៦៤.៦៥ និង ៦៧ នៃច្បាប់ភូមិបាល ។

ការបញ្ជាក់របស់លោក ជុំ សារ៉ាយ ទាំងពីរលើក ដោយពិនិត្យឃើញថាមានពាក់ព័ន្ធដី ដែលម្ចាស់ដីមិនដឹងថា គេលួចលក់ដីរបស់ខ្លួននោះ លោកក៏បានធ្វើលិខិតលេខ០១៥ រ.ស ចុះថ្ងៃទី០៩-០៤-៩៧ បដិសេធចោលការចុះហត្ថលេខាបញ្ជាក់លើកិច្ចសន្យាទាំងពីរចោល ។

ចំណុចដែលគួរឲ្យចាប់អារម្មណ៍ គឺ ឆាយ ម៉ន មានពាក្យសុំកាន់កាប់ដីធ្លីទំហំតែ៤៤A ១៥០០ម$^{២}$ ទេ តែពេលលក់ឲ្យ សេង សំណាង បែរជាមានផ្ទៃដី១៨៣៤០ម$^{២}$ លើស១២៤៤០ម$^{២}$ តើដីសល់បានមក

ពីណា? ។ មាត្រា ២៤ ច្បាប់ភូមិបាល ការលួចលាក់. អចលនវត្ថុរបស់អ្នកដទៃ ត្រូវជាប់គុកពី១ឆ្នាំ ទៅ៥ឆ្នាំ ។

**សំណូម** សុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ពិសេសចង្អុលបង្ហាញឲ្យសាលាឧទ្ធរណ៍ ហៅ លោក ឆាយ ម៉ន និង ឡៀប ឈួន មកបំភ្លឺ ។

មេធាវី គង់ សុភ័ក្រ : ខ្ញុំគ្មានអ្វីបន្ថែមលើសារណារបស់ខ្ញុំបាទឡើយ ។

មេធាវី មួង ធនលាភី នាងខ្ញុំសូមបន្ថែមលើសារណាពីរចំណុចទៀត គឺ ៖

១-ការទិញ-លក់ មានកិច្ចសន្យាត្រឹមត្រូវ ចុះហត្ថលេខាចៅសង្កាត់ ហើយដីដែលលើសមិនបានដីមួយកន្លែងផង ។

២- ប្រសិនបើតុលាការរកឃើញថា ដីដែលលើសមានទំហំយ៉ាងណានោះ គឺនាងខ្ញុំសូមឲ្យអ្នកស្រី សុខ ខឿន ជាអ្នកទទួល ខុសត្រូវ ។

-ក្រោយពីស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់លោក សេង រតនៈ លោក ទូច សាឡាស់ លោក គង់ សាខន សារណារបស់លោក ជុំ សារ៉ាយ ចម្លើយរបស់អ្នកស្រី សុខ ខឿន សារណារបស់លោក ឃួន, ផល្លារិទ្ធិ និង តា រដ្ឋាភិរម្យ និងសេចក្តីសន្និដ្ឋានរបស់លោក មេធាវី សេង រតនៈ មេធាវី លោក ជុំ សារ៉ាយ និង មេធាវី លោក តា រដ្ឋាភិរម្យ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៩ ចុះថ្ងៃទី១៤-០១-៩៩ របស់លោក សេង រតនៈ បណ្តឹងសាទុក្ខលេខ៦៥ ចុះថ្ងៃទី២៥-០២-៩៩ របស់លោក គង់ សាខន និងបណ្តឹងសាទុក្ខលេខ៦៨ ចុះថ្ងៃទី០១-០៣-៩៩ របស់លោក ទូច សាឡាស់ ត្រង់ចំណុចទី២ និងចំណុចទាំងមូលនៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកឡើងនេះមកជំនុំជំរះជានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថាលោក ឃួន ផល្លារិទ្ធិ និងលោកតា. រដ្ឋាភិរម្យ ពិតជាបានទិញដីទំហំ ២០.៤៦៤,១៩៦៣ម$^2$ នៅភូមិរោងចក្រសង្កាត់ ភ្នំពេញថ្មី ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ពីលោកសេង សំណាង និងប្រពន្ធឈ្មោះអ្នកស្រី សុខ ខឿន ហៅ ចេង ហើយ ដោយមានចៅសង្កាត់រង ឈ្មោះ ឃ្លាំង

សោភ័ណ ចុះហត្ថលេខាជួយដឹងឮ ។ ដូច្នេះការទិញលក់រវាងលោក ឃួន. ផល្លារិទ្ធិ លោក តា រដ្ឋាភិរម្យ ជាមួយ និងលោក សេង សំណាង អ្នកស្រី សុខ ខឿន ហៅ ចេង គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

យល់ឃើញថាលោក សេង សំណាង និងអ្នកស្រី សុខ ខឿន ហៅ ចេង នៅតែទទួលស្គាល់ការលក់ទិញដីជាមួយលោក ឃួន. ផល្លារិទ្ធិ និងលោក តា រដ្ឋាភិរម្យ ដដែលហើយដែលដីនេះលោកសេង សំណាង និងអ្នកស្រី សុខ. ខឿន ហៅ ចេង ក៏បានទិញបន្តពីលោកឆាយ ម៉ន លោក ឆាយ ម៉ន បានទិញបន្តពីលោក ឡៀប ឈួន និងប្រពន្ធឈ្មោះ អ្នកស្រី គុំ សាខឿន ។ ក៏បានទិញបន្តពីមន្ត្រីរាជការ នៅសង្កាត់ភ្នំពេញថ្មី មកដែរ ។

យល់ឃើញថា តតិយជនមួយចំនួន បានប្រគល់ប្រាក់ឲ្យ លោក ជុំ សារ៉ាយ ចៅសង្កាត់ ភ្នំពេញថ្មី ទិញដីឲ្យខ្លួនរួច លោក ជុំ សារ៉ាយ បានចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីស្រែចំនួន១៨៣៤០ ម២ ពីលោក ឆាយ ម៉ន ឲ្យលោក សេង សំណាង និងអ្នកស្រី សុខ សាខឿន ហៅ ចេង ។ ដូច្នេះយោងតាមមាត្រា៤៣ នៃក្រឹត្យច្បាប់លេខ៣៨ ក្រច ចុះថ្ងៃទី២៨-១០-៨៨ លោក ជុំ,សារ៉ាយ ត្រូវមានកាតព្វកិច្ចចំពោះតតីយជនទាំងនេះ ។

យល់ឃើញថាលោក ឆាយ.ម៉ន ក្តី លោក ឡៀប ឈួន និងអ្នកស្រី គុំ សាខឿន ក្តី ក៏មានការពាក់ព័ន្ធក្នុងការទិញលក់ដីនេះដែរ ដូច្នេះសាលាឧទ្ធរណ៍ត្រូវបញ្ចូលឈ្មោះទាំងនេះមកជា តតិយជនក្នុងរឿងនេះផងដែរ ។

យល់ឃើញថា តតិយជនទាំងអស់ ពុំបានប្តឹងទាមទារយកដីវិញទេ គឺទាមទារថ្លៃដីប៉ុណ្ណោះ ដូច្នេះ ចំណុចទី៣ នៃសាលក្រមតុលាការក្រុងភ្នំពេញ ដែលសាលាឧទ្ធរណ៍សម្រេចថា បានការហើយលោក ជុំ សារ៉ាយ ក៏ពុំបានប្តឹងសាទុក្ខដែរនោះ ចំណុចនេះបានចូលជាស្ថាពរហើយ ។ ម្យ៉ាងទៀតការណ៍ដែលសាលាឧទ្ធរណ៍សម្រេចឲ្យតតិយជនប្តឹងទារថ្លៃដីទៅលើកក្រោយវិញ ដោយមិនសម្រេចឲ្យហើយតែម្តងនោះ គឺជាការខុសឆ្គង ។

យល់ឃើញថា សាលាឧទ្ធរណ៍មានការភ័ន្តច្រឡំ ដោយពុំបានពិចារណាទៅលើឯកសារភស្តុតាងដែលតតិយជនឈ្មោះ សេង រតនៈ លោក គង់ សាខន លោក ទូច សាឡាស់ បានជូនសំអាងមកនៅនេះ ដែលជាហេតុនាំឲ្យខូចខាតផលប្រយោជន៍របស់តតិយជន ។

យល់ឃើញថា យោងតាមមាត្រា៤៩ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រច ចុះថ្ងៃទី២៨-១០-៨៨ លោក សេង សំណាង និងអ្នកស្រីសុខ ខឿន ហៅ ចេង ហើយនិងតតិយជនត្រូវនៅមានកាតព្វកិច្ច និងគ្នាតទៅទៀត ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ០២ ចុះថ្ងៃទី០៤-០១-៩៩ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រូវខ្លះនិងខុសខ្លះ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខអ្នកស្រី សុខ ខឿន ហៅ ចេង លោកសេង រតនៈ លោកគង់ សាខន លោកទូច សាឡាស់ កំបាំងមុខលោកឃួន ផល្លាវិទ្ធិ លោកតា រដ្ឋាភិរម្យ លោកជុំ សារ៉ាយ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។**

១-ទទួលបណ្តឹងសាទុក្ខលេខ១៩ ចុះថ្ងៃទី១៤-០១-៩៩ របស់លោកសេង រតនៈ បណ្តឹងសាទុក្ខលេខ៦៥ ចុះថ្ងៃទី២៥-០២-៩៩ របស់លោកគង់ សាខន និងបណ្តឹងសាទុក្ខលេខ៦៨ ចុះថ្ងៃទី០១-០៣-៩៩ របស់លោកទូច សាឡាស់ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ០២ ចុះថ្ងៃទី០៤-០១-៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងឃ្លាចុងក្រោយនៃចំណុចទី២ត្រង់ៈប៉ុន្តែចំណុចទី២,៤ និងទី៥ត្រូវបដិសេធចោលជាអាសារបង់ និងកែប្រែ ពន្ធសមាមាត្រជាថ្មី និងចំណុចទី ៣ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៨៥ ចុះថ្ងៃទី៣០-០៣-៩៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញត្រង់ចំណុចទី២, ៤ និងទី៥ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០ រៀល ដែលលោក ឃួន. ផល្លាវិទ្ធិ បានបង់រួចហើយ គឺ ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ៊ីងចំនួន៤០០០ រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០ រៀល សម្រាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥០០០ រៀល សរុប១៩០០០រៀល ហើយតម្រូវឲ្យលោក សេង សំណាង និងអ្នកស្រី សុខ ខឿន ហៅ ចេង សងប្រាក់ចំនួន ១៩០០០រៀល នេះទៅលោកឃួន ផល្លាវិទ្ធិ វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០ ។